ធនាគារជាតិ នៃ កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ.......................................................

# ព័ត៌មាន

កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជា បានរៀបចំកិច្ចប្រជុំ ស្តីពី "ការធ្វើអង្កេតលើឥណទាននិងវឌ្ឍនភាពទីផ្សារអចលទ្រព្យសម្រាប់ការវិភាគស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា" ក្រោមអធិបតីភាព លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា ។ កិច្ចប្រជុំនេះ ត្រូវបានចូលរួមដោយភាគីពាក់ព័ន្ធ រួមមាន តំណាងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលវត្ថុកម្ពុជា ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនអចលនទ្រព្យ សរុបចំនួនប្រមាណ ១៥០ រូប ។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីផ្សព្វផ្សាយអំពីសារៈសំខាន់នៃការរក្សាស្ថិរភាពហិរញ្ញវត្ថុ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងដើម្បីទទួលបានកិច្ចសហការនិងការគាំទ្រពីភាគីពាក់ព័ន្ធចំពោះធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់គុណភាពវិភាគនិងតាមដានស្ថិរភាពហិរញ្ញវត្ថុ ។

ជាលទ្ធផល តំណាងមកពីស្ថាប័នពាក់ព័ន្ធបានសម្តែងនូវការគាំទ្រ និងឆន្ទៈក្នុងការផ្តល់កិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជាដើម្បីប្រមូលទិន្នន័យ និងព័ត៌មាននានា សម្រាប់ជាធាតុចូលក្នុងការវិភាគស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា ដោយក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ។

*នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ*

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧